# មេរៀនទី ៩៨៖ សូលក្លាយទៅជាស្ដេច

១ សាំយូអែល ៨៖១-២២; ៩៖១-២; ១០៖១៧-២៤

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/K01wJLTtN9E

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/sdOncNUnREY

**គោលបំណង៖** ព្រះជ្រាបដឹងគ្រប់ការទាំងអស់។

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ១៣៩៖២** *“ទ្រង់ជ្រាបការដែលទូលបង្គំអង្គុយចុះ និងការដែលទូលបង្គំក្រោកឡើងផងទ្រង់ក៏យល់គំនិតរបស់ទូលបង្គំពីចំងាយដែរ។”*

**ចំរៀង** ( *យូធូបលីង* )៖

១. ខ្ញុំច្រៀងថ្វាយព្រះក្នុងដួងចិត្តខ្ញុំ https://youtu.be/1th9e8PKFxs

២. ស្ដេចលើស្ដេច https://youtu.be/CPBqHYVwm3M

៣. ទ្រង់ជាព្រះ https://youtu.be/JWTOzAqGcyI

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «ធ្វើតាមអ្នកដឹកនាំ»

១. ឲ្យកុមារអង្គុយជារង្វង់ទាំងអស់គ្នា



២. ជ្រើសរើសកុមារម្នាក់ឲ្យទៅឈរនៅខាងក្រៅថ្នាក់ ដើម្បីធ្វើជាអ្នកចាំទី ហើយជ្រើសរើសកុមារម្នាក់នៅខាងក្នុងរង្វង់ ដើម្បីធ្វើជាអ្នកនាំធ្វើកាយវិការ។

៣. នៅពេលដែលកុមារដែលជាអ្នកទាយត្រឡប់មកវិញ គេត្រូវទាយថា អ្នកណាជាអ្នកនាំកាយវិការនេះ។

៤. ប្រសិនបើអ្នកចាំទីទាយត្រូវកុមារដែលជាអ្នកនាំកាយវិការត្រូវធ្វើជាអ្នកចាំទីវិញម្ដង។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា វាមិនមែនជាការងាយស្រួលនោះទេ ក្នុងការដែលទាយថា នរណាជាអ្នកដឹកនាំនោះទេ ពីព្រោះថា យើងមិនដឹងរឿងគ្រប់យ៉ាងនោះទេ។ ប៉ុន្តែព្រះរបស់យើងទ្រង់ដឹងគ្រប់ការទាំងអស់ ហើយទ្រង់ដឹងពីអ្វីដែលល្អបំផុតសម្រាប់យើង។

## ៤. ការណែនាំមេរៀន

នៅក្នុងប្រទេសកម្ពុជាតើនរណាធំជាងគេ? តើនរណាដែលធំជាងនាយករដ្ឋមន្ត្រីទៀតនោះ? ចាស គឺស្ដេច។ គាត់មានឈ្មោះអ្វី? គាត់ជាស្ដេចនៅក្នុងប្រទេសយើង តើមានប្អូនណាស្គាល់គាត់ខ្លះ? ចុះតើស្ដេចស្គាល់ឈ្មោះរបស់អូនៗដែរឬទេ? ចាសពិតណាស់គាត់មិនអាចស្គាល់ឈ្មោះរបស់ប្អូនៗអស់នោះទេ។ ប៉ុន្តែមានស្ដេចមួយទៀត ដែលស្គាល់ឈ្មោះរបស់យើងទាំងអស់ ហើយជ្រាបរឿងយើងគ្រប់យ៉ាង។ ព្រះអង្គគឺជាស្ដេចរបស់យើង! ព្រះជ្រាបដឹងពីអ្វីដែលយើងចង់បាន ហើយព្រះអង្គដឹងពីអ្វីដែលយើងត្រូវការ ដើម្បីឲ្យយើងមានភាពរីករាយពិតប្រាកដ។ តើអ្នកនឹងជ្រើសរើសទុកចិត្តលើព្រះដែរឬទេ? ថ្ងៃនេះសុំឲ្យយើងបានស្វែងយល់ពីប្រជាជនអ៊ីស្រាអែលថា ពួកគេជ្រើសរើសធ្វើបែបណា។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ មានប្រទេសភាគច្រើនត្រូវបានគ្រប់គ្រងដោយស្តេច។ ស្តេចជាអ្នកគ្រប់គ្រងប្រទេសរបស់ពួកគេ ហើយពួកគេអាចធ្វើអ្វីក៏បាន ដែលពួកគេចង់ធ្វើ។ មនុស្សទាំងអស់ត្រូវតែស្តាប់បង្គាប់ស្តេចរបស់ពួគគេ។ ស្តេចគឺមានអំណាច ប្រសិនបើស្តេចនោះល្អប្រជាជនសប្បាយចិត្ត តែបើស្តេចនោះមិនល្អប្រជាជននឹងរងទុក្ខ។

តើអ្នកណាជាស្តេចរបស់សាសន៍អ៊ីស្រាអែល? ព្រះគឺជាស្តេចរបស់អ៊ីស្រាអែល។ ព្រះស្រឡាញ់ទាំងអស់ជ្រាបដឹងទាំងអស់ ហើយព្រះអង្គល្អជានិច្ច។ ព្រះអង្គជ្រាបដឹងអ្វីៗគ្រប់យ៉ាងល្អបំផុត ពីព្រោះព្រះអង្គគ្រប់លក្ខណ៍។

នៅក្នុងខគម្ពីរថ្ងៃនេះ ជនជាតិអ៊ីស្រាអែលបានសំរេចចិត្តថា ពួកគេចង់បានស្តេចមួយអង្គ។ នេះគឺមិនមែនជា គំនិតល្អទេ ពីព្រោះព្រះត្រូវធ្វើជាស្តេចរបស់ពួកគេ។ ប៉ុន្តែមនុស្សទាំងនោះមិនចង់បានព្រះធ្វើជាស្តេចរបស់ពួកគេទេ។ ពួកគេគិតថា ពួកគេដឹងជាងព្រះ។ ពួកគេចង់បានមនុស្សធ្វើជាស្តេចពួកគេជំនួសព្រះ។ សាំយូអែល ជាម្នាក់ដែលដឹងថាជាជំរើសដែលខុស គាត់បានព្យាយាមអស់ពីសមត្ថភាពរបស់គាត់ ដើម្បីបញ្ឈប់មនុស្សទាំងនោះកុំឲ្យសំរេចចិត្តខុស។ តាមពិតសូម្បីតែព្រះក៏មានបន្ទូលថាទេដែរ ពីព្រោះព្រះអង្គជ្រាបថាវាមិនល្អសំរាប់ពួកគេទេ។ ព្រះជ្រាបដឹងថា មនុស្សដែលគេជ្រើសជាស្តេចនឹងបង្កើតកំហុស ហើយនឹងធ្វើឲ្យប្រជាជនរងទុក្ខ។ សូមចាំថា ព្រះជ្រាបដឹងថាអ្វីដែលល្អ ហើយអ្វីដែលអាក្រក់ជាងយើង ប៉ុន្តែប្រជាជនអ៊ីស្រាអែលមិនស្តាប់តាមព្រះទេ។ ដូច្នេះ ចុងក្រោយព្រះបានប្រទានអ្វីដែលពួកគេចង់បាន។ ពួកគេបានរើសបុរសដែលមានកំពស់ខ្ពស់ និង រឹងមាំម្នាក់មានឈ្មោះ **ថាសូល** ដើម្បីមកធ្វើជាស្តេច។

ប្រជាជនសប្បាយចិត្តណាស់ ប៉ុន្តែសាំយូអែល និងព្រះជាម្ចាស់បាននិយាយថា “ជនជាតិអ៊ីស្រាអែល គួរតែ ស្តាប់បង្គាប់ព្រះ ពីព្រោះព្រះជ្រាបដឹងគ្រប់ការទាំងអស់។ ស្តេចដែលជាមនុស្សអាចនឹងមិនដឹងគ្រប់ការបានល្អទាំងអស់នោះទេ។ ប្រជាជនអ៊ីស្រាអែលធ្វើការជ្រើសរើសមិនបានល្អនោះឡើយ។

មានពេលជាច្រើននៅក្នុងជីវិតដែលយើងមិនដឹងថាអ្វីដែលល្អបំផុតសំរាប់ជីវិតយើងនោះឡើង។ យើងត្រូវតែធ្វើតាមមនុស្សដែលគេដឹងប្រសើរជាងយើង។ ប្រជាជនអ៊ីស្រាអែលមានសាំយូអែល តែពួកគេមិនបានស្តាប់គាត់ទេ។ យើងក៏ត្រូវតែចងចាំថា ព្រះជ្រាបដឹងអ្វីដែលល្អបំផុត។ យើងអាចជ្រើសរើសទុកចិត្តព្រះគ្រប់យ៉ាងនៅក្នុងជីវិតរបស់យើង។ ប្រជាជនអ៊ីស្រាអែលមិនបានទុកចិត្តព្រះទេ ហើយពួកគេបានសំរេចជ្រើសរើសជីវិត ដែលពិបាកសំរាប់ពួកគេ។ សូមធ្វើតាមព្រះ ព្រោះព្រះជ្រាបដឹងពីអ្វីដែលល្អសំរាប់យើង។

## ៦. សំនួរពិភាក្សា

១. នៅក្នុងព្រះគម្ពីរសញ្ញាចាស់ តើនរណាជាអ្នកគ្រប់គ្រងប្រទេស? *(ស្តេច)*

២. តើនរណាជាស្តេចរបស់ប្រជាជនអ៊ីស្រាអែល? *(ព្រះ)*

៣. តើប្រជាជនអ៊ីស្រាអែលបានសុំអ្វី? *(សុំមនុស្សឲ្យមកធ្វើជាស្តេច)*

៤. តើអ្នកណាប្រាប់ប្រជាជនអ៊ីស្រាអែលថាវាមិនមែនជាគំនិតល្អទេ? *(សាំយូអែល និងព្រះជាម្ចាស់)*

៥. តើនរណាដែលព្រះបានឲ្យធ្វើជាស្តេចរបស់ប្រជាជនអ៊ីស្រាអែល? *(សូល)*

៦.តើនឹងមានអ្វីកើតឡើងចំពោះប្រជាជនអ៊ីស្រាអែល ពេលដែលពួកគេរើសមនុស្សធ្វើជាស្តេចលើព្រះ? *(ពួកគេនឹងរងទុក្ខ)*

៧. តើនរណាជាស្តេចពិតប្រាកដរបស់អ្នក? *(ព្រះ)*

**៧. ល្បែងកំសាន្ត** «រទេះភ្លើង»



១. ឲ្យកុមារតោងចង្កេះគ្នាកុំឲ្យរបូត

២. រើសកុមារម្នាក់ដែលឈរនៅខាងមុខគេ ធ្វើជាអ្នកដឹកនាំ កុមារដែលជាអ្នកដឹកនាំគាត់ត្រូវនៅខាងមុខគេ គាត់ត្រូវនាំកុមារ រត់ កាត់កៅអី លូនក្រោមតុ លោត ចាក់គួរ។

៣. អ្នកតោងចង្កេះនោះត្រូវតែធ្វើតាមអ្នកដឹកនាំគ្រប់ជំហាន

៤. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា យើងត្រូវស្តាប់និងធ្វើតាមអ្នកដឹកនាំ។ ព្រះគឺជាអ្នកដឹកនាំដ៏ពិតនៅក្នុងការរស់នៅរបស់យើង ដូច្នេះយើងត្រូវតែស្តាប់តាម និងដើរតាមព្រះជានិច្ច។

**៨. ខគម្ពីរចងចាំ**

**ទំនុកដំកើង ១៣៩៖២** *"ទ្រង់ជ្រាបការដែលទូលបង្គំអង្គុយចុះ និងការដែលទូលបង្គំក្រោកឡើងផងទ្រង់ក៏យល់គំនិតរបស់ទូលបង្គំពីចំងាយដែរ។"*

**៩. ហត្ថកម្ម ផាត់ព៌ណ «សូលក្លាយទៅជាស្តេច»**

សូមបោះពុម្ពក្រដាសនៅទំព័រខាងក្រោម ឲ្យកុមារផាត់ពណ៌គ្រប់ៗគ្នា។

**១០. ចំរៀង** *( រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស )*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន )**
ព្រះយេស៊ូវមិនបង្ខំមនុស្សគ្រប់គ្នាឲ្យដើរតាមទ្រង់ទេ។ ព្រះអង្គចង់ឲ្យយើងស្រឡាញ់ព្រះអង្គដូចជាទ្រង់ស្រឡាញ់យើងដែរ។ យើងអាចជ្រើសរើសជីវិតអស់កល្បដោយធ្វើតាមទ្រង់តាមរយៈការស្តាប់បង្គាប់។ សូមអានព្រះគម្ពីរ **១សាំយូអែល** ៨:១៩-២១ ម្តងទៀត។ តើពេលណាដែលអ្នករឹងទទឹងទាមទារធ្វើតាមវិធីរបស់ខ្លួនឯងដូចជារាស្ត្ររបស់អ៊ីស្រាអែលបានធ្វើ? តើស្ថានភាពរបស់អ្នកចេញមកយ៉ាងដូចម្តេចដែរ? ព្រះស្រឡាញ់យើង យកចិត្តទុកដាក់ចំពោះយើង ហើយព្រះចង់ឲ្យយើងរស់នៅសំរាប់ទ្រង់។ ព្រះចង់ បានអ្វីដែលល្អបំផុតសំរាប់យើង។ សូមឲ្យយើងប្តេជ្ញាចិត្តដើម្បីស្វែងរកការដឹកនាំរបស់ព្រះ ហើយស្តាប់បង្គាប់ និងដើរតាមទ្រង់នៅក្នុងជីវិតយើង។

# សូលក្លាយទៅជាស្តេច



សូមសរសេរខគម្ពីរចងចាំៈ________________________________

________________________________________

________________________________________